

រឿងនិទានសម្រាប់កុមារ

# ចន្ទ្រាយឆោតល្ងង់



# A Silly Rabbit

បាក់ គឺជាទន្សាយមួយដ៏ឆោតល្ងង់ ហើយចូលចិត្តឡេះឡោះណាស់ ។ វាកំសាកណាស់ សូម្បីតែមានរឿងអ្វី បន្តិចបន្តួចក៏ខ្លាចដែរ ។ ថ្ងៃមួយ បាក់បានទៅដេកនៅក្រោមដើមដូងមួយ ។ ពេលបាក់ដេកលង់លក់ វាបានសុបិន ឃើញរឿងអាក្រក់មួយ ។ វាយល់សប្តិឃើញថា ផែនដីទាំងមូលកំពុងតែប្រេះបែក ។



Buck was a very silly and foolish . He was so timid that he would get scared of the silliest of things. One day, Buck was sleeping under a coconut tree. In his deep sleep, Buck dreamt a terrible dream. He saw that the whole Earth was cracking up!


នៅពេលនេះ ស្វាកំប្លែចមួយចំនួនកំពុងតែលេងនៅលើចុងដូង ដែលបាក់កំពុងតែដេកពីក្រោម ។ ស្វាទាំងនោះ កំពុងលោតជើងមួយជើងពីរនៅលើដើមឈើនេះ ។ រំពេចនោះ ស្រាប់តែមានសម្លេងធ្លាក់ ឮសូរក្តុក ។ នោះគឺជាសម្លេងធ្លាក់ផ្លែដូងដ៏ធំមួយមកលើដីក្បែរកន្លែងបាក់កំពុងតែដេក ។

បាក់បានភ្ញាក់ឡើងព្រោះសម្លេងធ្លាក់យ៉ាងខ្លាំងនេះ ហើយវាក៏ងើបអង្គុយខំផ្ទៀងស្តាប់ដោយបះត្រចៀកឡើងច្រូង ។ វាឆ្ងល់ក្នុងចិត្តថា "តើនេះជាសម្លេងអ្វីហ្ន៎ ?" ។ បន្តិចក្រោយមកក៏មានផ្លែដូងមួយទៀតធ្លាក់មកក្បែរខ្លួងវាតែម្តង ធ្វើឱ្យដីញ័ររញ្ជួយ ។ បាក់មិនបានងាកក្រោយមើលទាល់តែសោះ ហើយក៏ខំស្រែកថា "អូ!អូ!អូ! តិចលោផែនដី កំពុងតែប្រេះបែកទៅហ្ន៎ ។ សុបិនរបស់ខ្ញុំហាក់បីដូចជាឆុតណាស់!"



Now some naughty monkey were playing atop the coconut tree, under which Buck lay asleep. The monkeys jumped and hopped on the tree. Suddenly, there was a huge " THUD" It was the sound of a big coconut that fell onto the ground, just next to where Buck was sleeping.


Buck started up at this noise and sat straight, pricking his ears. "What could that sound be?" wondered he. And at that very moment, another coconut fell just behind Buck and shook the ground. Not bothering to look behind, timid Buck cried, "Oh, Oh, Oh! It seems that the Earth is cracking up ! My dream seems to come true!!"



ពិតឃើញដល់រឿងនេះ បាក់ស្ទុះក្រោកឡើង ហើយឆក់យកមួកវែងរបស់វា ខំរត់ទៅ
យ៉ាងល្បឿន ដោយនិយាយ តិចៗបណ្តើរថា "អូ!អូ!អូ!" ។ នៅពេលនោះមាន
ទន្សាយមួយទៀត ឈ្មោះថា ហ្វ្លាហ្វី វាកំពុងពាក់វ៉ែនតា ដេកហាលថ្ងៃនៅ
លើអង្រឹង របស់វាយ៉ាងសប្បាយរីករាយ ។ ហ្វ្លាហ្វីឃើញបាក់កំពុងតែ
រត់ហាក់ដូចជាមានសត្វឆ្កែ កំពុងតែដេញតាមចាប់វាអញ្ចឹង ។


With this thought in his mind, Buck jumped up, grabbed his tall hat and ran as fast as he could, All the while Buck kept muttering "Oh, Oh, Oh,!" Another rabbit, called Fluffy, was enjoying the afternoon sunshine, lying on a hammock, with his goggles on.

Fluffy saw Buck running as if some hound was after him.



នៅពេលបាក់រត់កាត់ ហ្វាហ្វី ស្រែកសួរទៅបាក់ថា "បាក់! ម៉េចក៏រត់ឈឿនម្លេះ?" បាក់តបដោយដង្ហក់ថា "កុំសួរខ្ញុំ" ហើយចេះតែរត់ទៅទៀត ។ ហ្វាហ្វីមានសេចក្តីងឿងឆ្ងល់កាន់តែខ្លាំង ហើយក៏ចេះតែរត់តាមបាក់ដែរដោយសារ ហ្វាហ្វី ចង់ដឹងថាមានរឿងអ្វីកើតឡើង ។ បាក់និយាយថា "ឯងមិនដឹងទេឬ ? ផែនដីនេះកំពុងតែប្រេះបែកហើយ ។"


As Buck running by, Fluffy called after him, “Buck, why are you running so fast?” “don’t ask me!” Buck cried, panting and still running. Curiosity got the better of fluffy and he ran after Buck, begging to know what was the matter . Buck said “Don’t you know? the Earth is all breaking up”



ឮបែបនេះ ហ្វាហ៊ីភ័យឡើងស្លេកស្លាំង ។ វាបោះវ៉ែនតាចោល ហើយរត់តាមបាក់ ។ ទន្សាយបន្តបន្ទាប់ទៀតនាំ គ្នារត់តាមហ្វាហ៊ី និងបាក់ បន្ទាប់ពីពួកគេបានឮថាផែនដីទាំងមូលកំពុងតែប្រេះបែក ។ រឿងនេះបានធ្វើឱ្យមានសត្វទន្សាយមួយហើយមួយទៀតរត់បន្តតាមពួកគេទាំងពីរ រហូតមានទន្សាយដល់ទៅរាប់រយរត់ពីក្រោយ ។

Hearing this, Fluffy became panicky. He threw away his goggle and off he ran, after Buck. The next rabbit they met followed them as well when he heard that the Earth was all breaking up. And in his way, one rabbit after another joined them, until there were hundreds of rabbit running as fast as they could go

ខណៈពេលដែលទន្សាយរាប់រយនេះកំពុងតែរត់ ពួកវាបានជួបនឹងសត្វក្តាន់មួយកំពុងស៊ីស្មៅនៅវាលមួយ ។ នៅពេលដែលសត្វក្តាន់ងើបក្បាលរបស់វាឡើងដើម្បីឱ្យដឹងថាមានរឿងអ្វីកើតឡើងនោះ សត្វទន្សាយនាំគ្នាស្រែក ព្រមៗគ្នា ។ ក្តាន់ស្តាប់មិនបានព្រោះសត្វទន្សាយទាំងអស់នាំគ្នាស្រែកព្រមគ្នា ។ ក្តាន់ភ័យស្លន់ស្លោ ហើយក៏រត់តាមទន្សាយទាំងអស់នោះដែរ ។




As these hundreds of rabbits were running, they passed by a deer, who was grazing in the meadows. When the deer raised his head to see what the matter was, the rabbits all cried in unison. The deer could not understand because all the rabbits spoke together. He panicked and followed the rabbits.




សត្វចចកបានឃើញហ្វូងសត្វទាំងនេះរត់ ។ បាក់គឺជាអ្នកនាំមុខហ្វូងរត់មារ៉ាតុងនេះ ហើយវាចេះតែស្រែកថា "អូ!អូ!អូ!" ។ ពេលចចកសួរ បាក់ ពីមូលហេតុ បាក់និយាយថា "ឯងពិតជាមិនដឹងទេឬ ផែនដីទាំងមូលកំពុង តែប្រេះបែក ហើយឈានដល់ទីបញ្ចប់ហើយ ។ បើឯងចង់រស់ រត់តាមពួកយើងមក ។" ចចកក៏រត់តាមពួកសត្វទាំងនោះដែរ ។

A fox saw this big crowd running. Ahead of this big marathon ran Buck, crying “oh, oh, oh” When the fox asked Buck the reason, he said, “Why, don’t you know that the world is cracking up and coming to an end ? If you want to save your life, run along with us.” So the fox too, joined the race.




រត់យូរទៅ ស្រាប់តែមានដំរីមួយមកចូលរួម
នឹងពួកគេដែរ ហើយអ្នករត់បន្ទាប់ទៀតគឺជា
សត្វរមាស ។ សត្វក្ងោកដែលកំពុងតែរាំនៅក្នុង
ព្រៃ បានឃើញហ្វូងសត្វទាំង នេះរត់ និងស្រែក
ព្រមគ្នាថា ផែនដីដល់ទីបញ្ចប់ហើយ! ហើយសត្វ
ក្ងោកក៏ចូលរួមក្នុង ការរត់មារ៉ាតុងនេះដែរ ។

On and on they ran, and very soon an elephant joined them. Next it was arhino, who was following them. The peacock, who was dancing in the wild, saw the huge crowd running, all screaming, "The world is coming to an end!!!" And the peacock too joined the marathon.



សត្វទាំងអស់នេះបានរត់កាត់តាមជម្រករបស់សត្វតោ ហើយស្រែកឡើងព្រមៗគ្នាថា "ពិភពលោកទាំងមូល កំពុងតែដល់ទីបញ្ចប់ហើយ! រត់ភ្លាមទៅ ដើម្បីរួចជីវិត ។" សត្វតោចេញពីជម្រករបស់វាមក មានសេចក្តីភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលបានឃើញ សត្វទាំងអស់នោះនាំគ្នារត់ដោយមានទឹកមុខតក់ស្លុតក្រៃលែងបែបនេះ ។


All these animals ran past by a lion's den, screaming, "All the world is coming to an end. Run to save your life."
The lion came out of his den and was very surprised to see all the animals running, with a look of fear over their faces.



សត្វតោគិតថា "អញឆ្ងល់ណាស់ ថាតើសត្វទាំងនេះនាំគ្នាធ្វើអ្វី? ប្រាកដជាមានអ្វីខុសពីប្រក្រតីមិនខានទេ ឬមួយប្រាកដជាមានពាក្យចចាមអារ៉ាមណាមួយហើយមើលទៅ។" គិតហើយ វាក៏រត់ទៅជើងភ្នំចំពីមុខសត្វទាំងឡាយ ដែលកំពុងរត់នោះតែម្តង ហើយក៏គ្រហឹមបីដង ។ ពេលឮសម្លេងគ្រហឹមស្តេចសត្វនេះ ហ្វូងសត្វទាំងនោះក៏ឈប់ភ្លាមតែម្តង។ តោបានសួរថា "ហេតុអ្វីក៏នាំគ្នារត់លឿនម្ល៉េះ ?" សត្វទាំងនោះឆ្លើយថា "ស្តេចតោអើយផែនដី នេះកំពុងតែប្រេះបែកហើយ។

'I wonder what these fools are up to ? there must be some terrible mistake or some gossip,' Thought the lion. So, he ran to the foot of a hill right in front of the running animals, and roared three times. Hearing the loud roar of the King of Beasts', the procession stopped at one. " Why are you running so fast?" asked the lion. "Oh, King lion," they answered him, "the Earth is all breaking up !"

តោបានសួរថា "អ្នកណាជាអ្នកឃើញផែនដីប្រេះបែក ?" ដំរីឆ្លើយថា "ខ្ញុំមិនដឹងទេ សួរបងចចកទៅ គាត់ជាអ្នក ប្រាប់រឿងនេះដល់ខ្ញុំ ។" ចចកឆ្លើយថា "ខ្ញុំមិនដឹងទេ សួរបងក្តាន់ទៅ គាត់ជាអ្នកប្រាប់ខ្ញុំ ។" ហើយនៅពេលដែលតោ សួរទៅសត្វក្តាន់ ក្តាន់ក៏បានឆ្លើយថា គឺសត្វទន្សាយ ។ ទន្សាយចង្អុលតៗគ្នា ដោយនិយាយថា "ខ្ញុំមិនបានឃើញ ព្រឹត្តិការណ៍នេះទេ ប៉ុន្តែទន្សាយមួយផ្សេងទៀតជាអ្នកប្រាប់ខ្ញុំ ។"




"Who saw it breaking up ?"asked the lion. "I didn't," said the elephant . " Ask the fox. He told me about." "I didn't" said the fox. "The deer told me about it." And when the deer was asked, he said, it was the rabbits. One after another, the rabbit pointed to the other, saying, "I did not see it, but another rabbits told me about it".

នៅទីបំផុត ស្តេចតោក៏បានសួរទៅបាក់ ។ បាក់ខំប្រមូលសេចក្តីក្លាហានឡើង ហើយ
បានដើរសំដៅទៅស្តេចតោដោយនិយាយថា "លោកម្ចាស់ ពេលខ្ញុំកំពុងដេកនៅក្រោម
ដើមដូង ខ្ញុំសុបិនថាផែនដីនេះកំពុងតែប្រេះបែក នៅពេលខ្ញុំឮសម្លេងក្អក ហើយកន្លែង
ដែលនៅជុំវិញខ្ញុំបានញ័ររញ្ជួយ ។ ខ្ញុំគិតថា ផែនដីកំពុងតែប្រេះបែកហើយ ហើយក៏
រត់តែម្តង ។"




At last, the lion came to Buck. Buck mustered up his courage and came forward to the lion and said “O king, I was sleeping under a coconut tree and was dreaming that the world was breaking up, when I heard a big “ THUD”! And then, there was another “THUD”, and the ground near me shook!! thought that the world was cracking up , and I run away.”

ស្តេចតោនិយាយថា "ឯង និងយើងត្រូវត្រឡប់ទៅកន្លែងដែលផែនដីចាប់ ផ្តើមប្រេះ បែក ដើម្បីឱ្យដឹងថាមានរឿងអ្វីកើតឡើងពិតប្រាកដ ។" រួចហើយ ស្តេចតោក៏ឱ្យបាក់ឡើងជិះលើខ្នងរបស់វា ហើយក៏ចេញទៅយ៉ាងលឿន ដូចព្យុះ។ ក្នុងពេលនោះ សត្វដទៃទៀតរង់ចាំពួកគេទាំងពីរនៅឯជើងភ្នំ ។



"Then," said the lion, "you and I will go back to the place where the Earth began to break up, and see what the mather is." So , the lion put Buck on his back, and away they went, like the wind. The other animals, meanwhile, waited for them at the foot of the hill.



នៅពេលស្តេចតោ និងបាក់ទៅដល់កន្លែងដែលបាក់ដេក ស្តេចតោដើរជុំវិញកន្លែងនោះ ហើយឃើញផ្លែដូងធំៗ ពីរនៅទីនោះ ។ ស្តេចតោបានងាកមើលទៅចុងដូងឃើញស្វាពីរ កំពុងមើលមកកាន់ពួកគេទាំងពីរនាក់ ។ មិនយូរប៉ុន្មាន ស្តេចតោដ៏ឆ្លាតវៃនេះក៏បានយល់ពីហេតុការណ៍នោះទាំងមូល ។

When the lion and Buck reached the spot where Buck was sleeping, the lion went round the place and saw two huge coconuts lying by. Then he looked up the coconut tree and saw two monkeys atop, looking down at them. It didn't take long for the clever to understand the whole incident.

ស្តេចតោបាននិយាយទៅកាន់បាក់ថា "ហេតុអ្វីក៏ឯងភ្លើបែបនេះ! សម្លេងដែលឯងបានឮនេះជាសម្លេងផ្លែដូង ធ្លាក់មកលើដីទេតើ! ហើយផែនដីញ័រក៏ព្រោះតែផ្លែដូងទាំងពីរនេះធ្លាក់មកលើដីនេះឯង!!។" ក្រោយមកស្តេចតោបានត្រឡប់ទៅ រកសត្វដទៃទៀត ហើយបានប្រាប់ ពួកគេអំពីហេតុការណ៍ដែលបានកើតឡើងពិតប្រាកដ ។

សត្វទាំងអស់នាំគ្នាអស់សំណើចនឹងភាពល្ងង់ខ្លៅគ្មានចេះពិចារណារបស់ខ្លួន ហើយក៏ នាំគ្នាត្រឡប់ទៅផ្ទះវិញ ។



The lion said to Buck, "Why, you fool! It must have been the sound of the coconut falling to the ground that you heard! And the Earth shook because those two coconuts fell onto the ground!!" Then the lion went back to the other animals, and told them all about what had actually happened. All the animals laughed at their own foolishness and returned home.